ភ្នំពេញ , ថ្ងៃទី ២៨ ខែ កក្កដា ឆ្នាំ ១៩៩៣

# អនុក្រឹត្យលេខ ០៤ អ.ន.ក្រ
# ស្តីពីឯកសណ្ឋាន និង ផ្លាកសញ្ញាកងទ័ពជាតិកម្ពុជា

* * * *

## សហប្រធាននៃរដ្ឋាភិបាលជាតិបណ្តោះអាសន្នកម្ពុជា

* * * *

- យោងតាមក្រឹត្យ ចុះថ្ងៃទី ០២ ខែ កក្កដាឆ្នាំ១៩៩៣ ស្តីពីការតែងតាំងរដ្ឋាភិបាល ជាតិបណ្តោះអាសន្ននៃកម្ពុជា
- យោងតាមក្រឹត្យ ចុះថ្ងៃទី ០៣ ខែ សីហា ឆ្នាំ ១៩៩៣ ស្តីពីសញ្ញាឋាននូវសក្តិកងទ័ពជាតិកម្ពុជា
- យោងតាមក្រឹត្យស្តីពីរូបភាព និង ខ្នាតលំដាប់សក្តិកងទ័ពជាតិ
- យោងតាមសំណើររបស់រដ្ឋមន្ត្រីក្រសួងការពារជាតិ និង អគ្គសេនាធិការកងទ័ពជាតិកម្ពុជា

## សម្រេច

មាត្រា ១ : - ត្រូវបានរៀបចំឯកសណ្ឋានកងទ័ពជាតិប្រភេទទ័ពជើងគោកដូចខាងក្រោម :

**រូបភាព និង ខ្នាតឯកសណ្ឋាន :**

ក- ឯកសណ្ឋានថ្នាក់ឧត្តមសេនីយ៍ មានចំនួន ៧ សំរាប់ពី :

១- ឯកសណ្ឋានធំលេខ ១ " កុដស "

អាវកុដសកត្រង់ ខោក្រមៅឆ្នូតក្រហម ពីរ ម្ហូកធំពណ៌ខ្មៅសំរាប់ពាក់ក្នុងពិធីបុណ្យជាតិធំៗ និងពិធីក្នុងព្រះបរមរាជវាំង ។

**រូបភាព និង ខ្នាត :**

- អាវកុដសកត្រង់កាត់រាងអាវធំ គ្មានផែកខ្នង កអាវមានប៉ាក់ ដូចផ្លេកព្រៃឈើ ពណ៌មាសជុំវិញលើស្មាមាន ប៊ូល ហោប៉ៅ ៤ " ពីខាងលើដេរប៉ះ ចំកណ្តាលមានចាប់ផ្តត់មួយ តំរបរាងស្លឹកពោធិ៍ពីខាងក្រោម ដេរបង្កប់មាន តំរបរាងចតុកោណកែង " អាវដៃវែង លើផ្នែរបត់ដៃអាវមានប៉ានក្រណាត់ពណ៌ មាសទំហំ ៨ ម.ម ឡើងមានរូប ព្រះសង្ហារពណ៌មាសចំនួន ៧ នៅចុងដៃអាវមានឡេវបញ្ចោត បី ។

- ខោជើងវែងចង្កេះត គ្មានក្លី នៅខាងក្រោយមានហោប៉ៅមួយ ដេរបង្កប់គ្មានតំរប ហោប៉ៅ ពីរ ដេរបង្កប់ នៅចំហៀងតាមផ្នែរខោ មានប៉ានក្រហមពីរ ប៉ាននិមួយៗ មានទទឹង ២ ស.ម ។

- ម្ហូក កាស្កេត ខាងលើក្រណាត់ គាំទ្រ ពណ៌ក្រមៅ ជើងម្ហូកនិងហាមពណ៌ខ្មៅ វ័ន្ត និងឡេវរូប

[illegible]

- ខ្សែឥស្សរយសពណ៌មាសវេញចូលគ្នាបីខ្សែអមចិ មានចន្លោតខ្ទុលពីរពណ៌មាសពាក់លើស្មាស្តាំ ។

- ស្បែកជើងស្បែកខ្លី ពណ៌ខ្មៅ ចងខ្សែ ស្រោមជើងខ្មៅ ស្រោមដៃស ។

**២ - ឯកសណ្ឋានធំលេខ ២ :**

សំរាប់ពាក់ក្នុងពេលធ្វើមិទ្ទិញ បំពេញបេសកកម្មនៅក្រៅប្រទេស ទទួលភ្ញៀវជាតិ អន្តរជាតិ អាវខោនិងមួក ក្រណាត់តេហ្គាល់ ពណ៌តឺរ ។

**- រូបភាព និង ន្ទិន :**

- អាវកាត់រាងអាវ វ៉ារីមានផែកខ្នង កបើក ប៉ូលស្មា មានហោប៉ៅបួន ដេរប៉ះ « ហោប៉ៅពីរ លើ ដេរចត់ផ្នត់កណ្ដាល គំរបរាងស្លឹកពោធិពីរ ខាងក្រោម គំរបរាងចតុកោណកែង » ឡេវ ៤ មានរូបព្រះសង្ហាពណ៌មាស អាវដៃវែង ចុងដៃអាវមានដាក់ឡេវចញ្ចោតចិ » ។

- ខោជើងវែងឆ្វេរបង្កប់ ចង្កេះតឆ្មានក្លី មានហោប៉ៅបួន « ខាងក្រោយពីរដេរបង្កប់ គំរបរាងស្លឹកពោធិ នៅចំហៀងពីរ ដេរបង្កប់តាមឆ្វេរខោ »។

- មួកកាស្កេត ក្រណាត់តេហ្គាល់ពណ៌តឺរ ជើង និង អោមមួកពណ៌ខ្មៅ វ័ន្តមួក និង ឡេវ មានរូបព្រះសង្ហា ពណ៌មាស លើអោមមួកមានជាក់ក្បាច់ភ្ញីទេសឌិនពណ៌មាសដល់ជើងមួក ។

- អាវសឺមី ក្នុងគខុប ក្រណាត់តេតារ៉ុង ពណ៌ស ពាក់នៅពេលរាត្រី នៅពេលថ្ងៃ ពណ៌តឺរ អាវដៃវែង មានហោប៉ៅមួយ គ្មានគំរប កាត់ស្រុងវែង ដាក់ក្នុងខោ ។

- ក្រវ៉ាត់កពណ៌ខ្មៅ ស្រោមដៃពណ៌ស ។

- ស្បែកជើងស្បែកពណ៌ខ្មៅ កខ្លី ចងខ្សែ ស្រោមជើងពណ៌ខ្មៅ ។

- ខ្សែក្រវ៉ាត់ពណ៌តឺរ ក្បាលខ្សែក្រវ៉ាត់ពណ៌មាសលោត ។

- ខ្សែឥស្សរយសពណ៌មាស « ដូចខាងលើ » ។

* ចំពោះយុទ្ធនារី អាវដូចគ្នាខាងលើ តែជីពចង្កេះ និង កអាវរាងនារី សំពត់ហ្ស៊ីបក្រោមជង្គង់ ។

**៣- ឯកសណ្ឋានលេខ ៣ « ចាយហារីតើន » :**

- សំរាប់ពាក់ក្នុងពិធីការ ដូចជាបើកបិទវគ្គរៀនសូត្រ ពិធីសមោសរ និង ជប់លៀង ។ ល។ អាវនិងមួកក្រណាត់ តេហ្គាលពណ៌តឺរ ខោក្រណាត់តេហ្គាលពណ៌គ្រេអ៊ី ។

**រូបភាព និង ន្ទិន :**

- អាវដៃខ្លីកបើក ហោប៉ៅបួន « ពីខាងលើដេរប៉ះគំរបរាងចតុកោណកែង ពីខាងក្រោមដេរយោគមកក្រៅ មានគំរបរាងចតុកោណកែង » ប៉ូលស្មា ខ្នងជីពក្លី ២ គ្មានផែកឡេវធម្មតាពណ៌តឺរ នៅចង្កេះមានក្រវ៉ាត់ជាប់អាវទំហំ ៦ ស.ម ក្បា[illegible] វ៉ាត់រាងពងក្រពើ មានរូបម្កុដ ព្រះខ័នមានពានទ្រ ។

- ខោជើងវែងក្រណាត់តេហ្គាលព[illegible] « ម៉ូតដូចឯកសណ្ឋានធំលេខ ២ » ។

- មួកស្បែកជើង និង ស្រោមជើង " ដូចឯកសណ្ឋានធំលេខ ២ " ។

* ចំពោះនារីអាវកបើក ពាក់ចង្កេះតាមរាងនារី សំពត់ហ្ស៊ីបក្រោមជង្គង់ ។

**៤ ឯកសណ្ឋានការងារដៃខ្លីពណ៌តឺរ :**

សំរាប់ពាក់ធ្វើការក្នុងការិយាល័យ ក្នុងមន្ទីរ និង ទាក់ទងស្ថាប័ននានាក្នុងប្រទេស ។

**- រូបភាព និង ខ្លឹម :**

- អាវដៃខ្លីក្រណាត់តេហ្គាលពណ៌តឺរកខុប ប៉ូលីស្មា គាត់ស្រុងវែងដាក់ក្នុងខោ ហោប៉ៅ ពីរ ដេរប៉ះចំកណ្តាល ដេរបត់ផ្នត់មួយមានគំរបរាងស្លឹកពោធិ ខ្សែក្រវាត់ពណ៌តឺរ ។

- ខោ និង មួកក្រណាត់តេហ្គាលពណ៌ក្រណាត់ និង ម៉ូតដូច មួក និងផ្លែមានចំពណ៌ទឹកមាសពាក់បញ្ចិតខាងស្តាំ ។

* ចំពោះនារីអាវដូចបុរស សំពត់ហ្ស៊ីបក្រោមជង្គង់ ឬ ខោឡេវចំហៀង ។

**៥ - ឯកសណ្ឋានការងារអាវដៃខ្លីពណ៌ត្រៃអ៊ឺ :**

ក្រណាត់តេហ្គាលពណ៌ត្រៃអ៊ឺ ដូចឯកសណ្ឋានការងារដៃខ្លីខាងលើ តែខុសពណ៌ត្រៃអ៊ឺ អាវកបើក និង ក្រវាត់ ចង្កេះទីហ៊ំ ៦ ស.ម ។

**៦ - ឯកសណ្ឋានការងារដៃវែងពណ៌តឺរ :**

សំរាប់ពាក់ដូចឯកសណ្ឋានការងារដូចខាងលើ ។

**- រូបភាព និង ខ្លឹម :**

- អាវដៃវែងកខុប ប៉ូលីស្មា ហោប៉ៅពីរ " ដូចខាងលើ " អាវដៃវែងគាត់ស្រុង វែងដាក់ក្នុងខោ "

- ខោ មួក ស្បែកជើងដូចឯកសណ្ឋានការងារ អាវដៃខ្លីពណ៌តឺរ ។

**៧ - ឯកសណ្ឋានប្រយុទ្ធ :**

សំរាប់ពាក់ពេលប្រតិបត្តិការ ហ្វឹកហាត់ និង ចុះបេសកកម្ម ។ ឯកសណ្ឋានពណ៌ត្រៃអ៊ឺ " ទ័ពពិសេស និង ទ័ពឆត្រយោងពណ៌ជាំ " រួមមាន ២ សំរាប់ ៖ មួយសំរាប់អាវហោប៉ៅបួន មួយសំរាប់ទៀត អាវហោប៉ៅពីរ " ។

**- រូបភាព និង ខ្លឹម :**

- អាវដៃវែងកបើក ថ្នេរខុប ប៉ូលីស្មា ហោប៉ៅបួនដេរហោត មានគំរបរាងចតុកោណកែង ឡេវចង្កប់នៅចុងដៃអាវ រង្វង់កដៃបំពង់មានឡេវក្រវាត់ ខ្សែក្រវាត់ធំ " សាំងទ្យេរ៉ុង " ក្រវាត់នៅចង្កេះពីលើអាវ ។

- អាវដៃខ្លីកបើក ថ្នេរខុប ប៉ូលីស្មា ហោប៉ៅពីរដេរហោត មានផ្នែកកណ្តាល គំរបរាង ចតុកោណកែង ដេរស្រុងដាក់ក្នុងខោ ឡេវចង្កប់ ។

៤ - កងកិច្ចិយសប្រើដាវ ពាក់ឯកសណ្ឋានធំលេខ ១ ថ្នាក់អនុសេនីយ៍ប្រើដាវមានស្រោមពណ៌សខ្សែរំយោល ដាវពណ៌មាស ដងដាវឆ្លាក់រូបព្រហ្ម ផ្លែដាវពណ៌ទឹកប្រាក់ ចង្កុំ និង ដងដាវក្បាច់ពណ៌មាស ។

មាត្រា ៤ : - ត្រូវបានរៀបចំផ្លាកសញ្ញាកងទ័ពជាតិដូចខាងក្រោម ÷

**ក - រូបព្រះសង្ហា :**

រូបព្រះសង្ហាយកតាមសម័យសង្គមរាស្ត្រនិយម ធ្វើពីលោហធាតុពណ៌មាស សំរាប់ពាក់លើមួកកាស្កេត និង ស៊ូកាស ទំហំកំពស់ ៧,៨ ស.ម ទទឹង ៦ , ៥ ស.ម ។ សំរាប់ពាក់លើមួកហ្សេកពីបោនេ មួកប៉ារ៉ាមធំ និង បេរ៉េ កំពស់ ៥ ស.ម ទទឹង ៤ ស.ម ។

**ខ - ផ្លាកសញ្ញាកងទ័ពជាតិ :** មានពីរប្រភេទគឺ ÷

១ - ផ្លាកសញ្ញាពាក់លើដៃអាវស្តាំ ចុះពីលើថ្នេរសា ៥ ស.ម មានរាងមូលបន្ទាត់ផ្ចិត ៨ ស.ម ស្រទាប់ខាងក្រៅពណ៌ស និហំ ៣ ម.ម នៅខាងលើ ១/៤ ពណ៌ខៀវសរសេរអក្សរ « កម្ពុជា » កំពស់អក្សរ ៧ ម.ម នៅខាងក្រោម ១/៤ ពណ៌ខៀវសរសេរអក្សរពណ៌ស « កងទ័ពជាតិ » កំពស់អក្សរ ៦ ម.ម នៅចំកណ្តាល ១/២ នៃរង្វង់ពណ៌ ក្រហម កណ្តាលមានប្រាសាទអង្គរវត្តកំពូល ៣ ពណ៌ស កំពស់ប្រាសាទកណ្តាល ២,៥ ស.ម បាត ៤ ស.ម ។

២ - ផ្លាកសញ្ញារូបហនុមាន ធ្វើរាងជាមេដៃពាក់បន្តោកនៅឡើវហោជៅអាវខាងស្តាំ ធ្វើរាងមូលពីព័រស៊ីឡែន មានបន្ទាត់ផ្ចិត ៣ , ៥ ស.ម ផ្ទៃបៃតងហនុមានកាន់ព្រះខ័នពណ៌មាស មានស្បែកសំរាប់បន្តោកប្រវែង ៨ ស.ម ខាងក្រោមសរសេរអក្សរកាត់ « ក.ឆ.ជ.ក » ។

**គ - ផ្លាកឈ្មោះ** មានពីរប្រភេទ :

១ - ផ្លាកជ័រប្លាស្ទិច ពណ៌បៃតង គូសបន្ទាត់ជុំវិញ និង អក្សរពណ៌លឿងបណ្តោយ ១០ ស.ម ទទឹង ២ ស.ម កំពស់អក្សរ ១០ ម.ម សរសេរអក្សរខ្មែរមួយ និង អក្សរឡាតាំងមួយ នៅខាងដើមឈ្មោះ សរសេរកាត់ពីឋានន្តរសក្តិរបស់នាយទាហាន នាយទាហានរង និងពលទាហាន : ឧត្តមសេនីយអក្សរកាត់ " ឧ " វរសេនីយ " វ " អនុសេនីយ " អ " នាយទាហានរង និងពលទាហាន " ព " កំពស់អក្សរ ៧ ម.ម សំរាប់ពាក់លើឯកសណ្ឋានធំ និង ឯកសណ្ឋានការងារពាក់លើហោជៅអាវខាងស្តាំ ។

២ - ផ្លាកឈ្មោះធ្វើក្រណាត់ ពណ៌ត្រែអ៊ី ដេរភ្ជាប់អាវ បណ្តោយស្មើមាត់ ហោជៅ ទទឹង ២ ស.ម សរសេរអក្សរពណ៌ខ្មៅ សំរាប់ដាក់លើឯកសណ្ឋានប្រយុទ្ធ កំពស់អក្សរ និង កន្លែងពាក់ដូចផ្លាកខាងលើ ។

ា ៥ : ចំពោះឯកសណ្ឋានកងអាវុធហត្ថជាតិកម្ពុជា ទ័ពជំនាញ និង សញ្ញាសំគាល់ ប្រភេទទ័ពមានការកំណត់ដោយឡែក ។

ា ៦ : សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីការពារជាតិ និង នាយអគ្គសេនាធិការកង ទ័ពជាតិត្រូវអនុវត្តអនុក្រឹត្យនេះ ។

ត្រា ៧ : អនុក្រឹត្យនេះចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្ថលេខា និង ចុះហត្ថលេខាតទៅ ។

**សហប្រធាន**

រដ្ឋាភិបាលជាតិបណ្តោះអាសន្ននៃកម្ពុជា

ព្រះហស្ថលេខា ហត្ថលេខា និង ត្រា

ស្តេចក្រុមហ្លួង នរោត្តម រណឫទ្ធិ ហ៊ុន សែន

* * * *